ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាលសរុប

# **កំណត់ហេតុ**
# **ប្រជុំពិភាក្សាស្តីពី**
# **ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស និងនាយកដ្ឋានស៊ើបអង្កេតពិសេស DSI**

ថ្ងៃចន្ទ មួយរោច ខែពិសាខ ឆ្នាំច សំរិទ្ធស័ក ព.សពីរពាន់ប្រាំរយហុកសិបពីរ ត្រូវនឹងថ្ងៃទីសាមសិប ខែមេសា ឆ្នាំពីរពាន់ដប់ប្រាំបី វេលាម៉ោងដប់ និងដប់ប្រាំនាទីព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សាស្តីពី ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃព្រះរាជាណាចក្រកម្ពុជា និងនាយកដ្ឋានស៊ើបអង្កេតពិសេស Department of Special Investigation ( DSI ) តំណាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃ។

**សមាសភាពក្រុមការងារទាំងពីរមានដូចជា៖**

១.ភាគី ព្រះរាជាណាចក្រកម្ពុជា

| | | |
|---|---|---|
| -លោកជំទាវ | **រ៉ន សិរីលក្ខិណា** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| -លោកជំទាវ ឧត្តមសេនីយ៍ឯក | **ប៉ុណ្ណ សំខាន** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| -ឯកឧត្តម ឧត្តមសេនីយ៍ទោ | **ជីវ ផល្លី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ |
| -លោក ឧត្តមសេនីយ៍ត្រី | **កែវ សុវណ្ណារ៉ា** | ប្រធានក្រុមការងារបង្ការទប់ស្កាត់ |
| -លោក វរសេនីយ៍ឯក | **អ៊ិន មាន** | ប្រធាននាយកដ្ឋាន( ស្តីទី ) |

១.ភាគី ព្រះរាជាណាចក្រថៃ

| | | |
|---|---|---|
| -Mr. | ARIT Tatsaphan | Head of Human Trafficking |
| -Miss. | Kannapat Korn | Special Case Inquiry Official |
| -Mr. | Peerawus Passata | Special case Officer |
| -Ms. | Kanika Suksomnil | Special Case Inquiry Official |
| -Ms. | Yosson Ruarg Sunnyamsiri | Special case Officer |

លោកជំទាវ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍ចំពោះវត្តមានរបស់គណៈប្រតិភូថៃ ( DSI ) និងមន្ត្រីពាក់ព័ន្ធទាំងអស់ដែលបានអញ្ជើញចូលរួមប្រជុំ

ពិភាក្សានាពេលនេះ ។ លោកជំទាវ មានប្រសាសន៍អំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជូនគណៈប្រតិភូថៃ និងបានថ្លែងអំណរគុណដល់ក្រុមការងារ DSI មានទំនាក់ទំនងគ្នាបានល្អ និងបានផ្តល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមករវាងប្រទេសទាំងពីរផងដែរ ។

លោក Arit Tatsaphan ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងស៊ើបអង្កេតពិសេសរបស់ប្រទេសថៃ បានធ្វើបទបង្ហាញបញ្ចាំងវីដេអូ អំពីតួនាទី ភារកិច្ចរបស់ DSI ។ កន្លងមក DSI ធ្លាប់បានប្រជុំពិភាក្សាលើការងារនេះច្រើនដងរួចមកហើយមានការសហការគ្នាបានល្អ។ តាងនាមឲ្យ DSI ខ្ញុំសូមថ្លែងអំណរគុណចំពោះ ក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ភាព កក់ក្តៅក្នុងការទទួលស្វាគមន៍ក្រុមការងារយើងខ្ញុំ។ បន្ទាប់ពីការបញ្ចាំង វីដេអូចប់ លោកជំទាវ រ៉ន សិរីលក្ខិណា បានសួរសំនួរពាក់ព័ន្ធនឹងជនជាប់ទោសដោយអំពើជួញដូរមនុស្ស ថា៖ **ចំពោះអ្នកប្រព្រឹត្តបទល្មើសក្នុងប្រទេសថៃ តើអាជ្ញាធរថៃអនុវត្តយ៉ាងដូចម្តេចចំពោះជនបរទេសផ្ទាល់?**

កន្លងមកខាង DSI បានស្នើមកខាងភាគីកម្ពុជា ធ្វើការសហការជាមួយនគរបាលខេត្តកំពង់ធំដើម្បីធ្វើការស្រាវជ្រាវរកទីលំនៅរបស់ពួកគេ(ការបញ្ជាក់អត្តសញ្ញាណ) ជនល្មើសរស់នៅទីណាដើម្បីធ្វើការសហការចាប់ខ្លួនជនល្មើសនោះផងដែរ។ កន្លងមន្ត្រីតុលាការបានកាត់ទោសអ្នកបញ្ជូនពលករទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ខុសច្បាប់ ហើយសូមឲ្យខាងភាគីកម្ពុជា ផ្តល់ព័ត៌មានពីចំណុចសំខាន់ៗបន្ថែមទៀតពីករណីនៅខេត្តកំពង់ធំ ។ រាល់ការចាប់ខ្លួនជនប្រព្រឹត្តបទល្មើសជាជនបរទេសក្នុងប្រទេសថៃគឺត្រូវចាប់ខ្លួនជាមុនសិន បន្ទាប់មកធ្វើសេចក្តីរាយការណ៍ជូនស្ថានទូតរបស់ពួកគេផ្ទាល់តែម្តង។ រយៈពេលពីរសប្តាហ៍កន្លងមកនេះខាង DSI បានទស្សនៈកិច្ចនៅកម្ពុជាដើម្បីពិភាក្សាការងារពាក់ព័ន្ធពលករកម្ពុជាទៅធ្វើការនៅប្រទេសថៃ និងម៉ាឡេស៊ី។ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ បានធ្វើការស៊ើបអង្កេតករណីកម្មករនេសាទសមុទ្រនៅប្រទេសម៉ាឡេស៊ី និងលើកយកករណីពិសេសមួយមកធ្វើការស្រាវជ្រាវជាក់ស្តែង ដោយមានបទល្មើសជួញដូរនៅទីនោះ ទើបខាង DSI មានការជួបប្រជុំពិភាក្សាការងារជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សផងដែរ។ យើងបានធ្វើដំណើរទៅខេត្តស្រះកែវ ជួបពលករទៅធ្វើការនៅប្រទេសម៉ាឡេស៊ីចំនួន ០៥នាក់ ដើម្បីធ្វើការសម្ភាសន៍អ្នកទាំងអស់នោះ ត្រូវបានជួញដូរកម្លាំងពលកម្ម ហើយខាងអាជ្ញាធរទាំងពីរគួរតែរៀបចំចាត់បញ្ជូនពួកគេមកប្រទេសដើមវិញ ដោយមានរៀបចំកិច្ចសម្ភាសន៍ផ្ទាល់ពីអង្គភាព DSI មន្ទីរពេទ្យរោគចិត្តសាស្ត្រ ។

**ឯកឧត្តម ឧត្តមសេនីយ៍ទោ ជីវ ផល្លី អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** តំណាងភាគីកម្ពុជាបានធ្វើសេចក្តីរាយការណ៍អំពីការងារបង្ក្រាបកន្លងមក នៅឆ្នាំ២០១៧ មានច្រើនករណីដូចជាការបង្ក្រាបចាប់ខ្លួនជនល្មើសដោយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប (ឈ្មោះ សឿ កែវ ឆ្នាំ២០១៦, ហឿន ម៉ៅ ឆ្នាំ២០១៧, នៅខេត្តកំពង់ធំមានចំនួន ០៣នាក់ ដោយក្រុមការងារនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃ បានចុះចាប់ដោយផ្ទាល់

(ឈ្មោះ ហឿន ម៉ៅ នៅខេត្តសៀមរាប ជនសង្ស័យនេះមានដីការចាប់ខ្លួន ឥឡូវបានគេចខ្លួនបាត់ហើយ ។ យើងកំពុងស្វែងរកចាប់ខ្លួនបន្ត មានឈ្មោះ វណ្ណា មានទីលំនៅក្នុងខេត្តសៀមរាប និង ឈ្មោះណាង រស់នៅខេត្តបន្ទាយមានជ័យ យើងបានសហការជាមួយអង្គការ (IJM) ជួយជម្រុញឲ្យអាជ្ញាធរដែនដីដើម្បីស្វែងរកទីលំនៅរបស់ពួកគេ នៅពេលពួកគេចូលមកកម្ពុជាត្រូវជម្រុញឲ្យមានការចាប់ខ្លួនពួកគេ។

Mr.Arit Tatsaphan ប្រធាន DSI តំណាងភាគីថៃ បានស្នើសុំភាគីកម្ពុជា គឺអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ធ្វើការសហការជាមួយអាជ្ញាធរខេត្តកំពង់ធំ ដើម្បីធ្វើការស្រាវជ្រាវរកអត្តសញ្ញាណរបស់ពួកគេដើម្បីធ្វើការចាប់ខ្លួន។

បន្ទាប់ពីកិច្ចប្រជុំបញ្ចប់ ក្រុមការងារគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងខាងប្រតិភូថៃ(DSI) បានចូលរួមសំណេះសំណាលបន្តទៀតជាមួយថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមាន **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង **ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង សំអាត** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។ ដោយមានការស្នើសុំពីខាងភាគីថៃ ជួយអន្តរាគមន៍លើករណីនេះ យើងរីករាយជាមួយខាងភាគីថៃ ដើម្បីធ្វើការស្រាវជ្រាវករណីនេះឲ្យបានជោគជ័យ។

កិច្ចប្រជុំពិភាក្សារវាងក្រុមការងារទាំងពីរ បានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងម្ភៃនាទី ថ្ងៃខែឆ្នាំដដែល ។

ថ្ងៃអង្គារ ០២រោច ខែពិសាខ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨

**អ្នកធ្វើកំណត់ហេតុ**

kamp

ម៉ុ. ១២ស

**គោរពជូន**

**លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃអង្គារ ០២រោច ខែពិសាខ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៨

**ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប**

ឧត្តមសេនីយ៍ទោ. គង់ - ពុទ្ធី

បានឃើញ
ថ្ងៃ១៨០៥
18/05/18

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
អគ្គលេខាធិការដ្ឋាន

# បញ្ជីវត្តមាន

ថ្ងៃ ចន្ទ ១១ កើត ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១

ត្រូវនឹងថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៨

ប្រជុំស្តីពី ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

| ល.រ | នាម គោត្តនាម/Name | ភេទ/Sex | តួនាទី/Position | អង្គភាព/Organization | លេខទូរស័ព្ទ/Phone | ហត្ថលេខា/Sign |
|---|---|---|---|---|---|---|
| 1 | លោកជំទាវ ជូ ប៊ុនអេង | ស្រី | អនុប្រធានអចិន្ត្រៃយ៍ | គណៈកម្មាធិការជាតិ គ ជ ប ជ | 012 872 639 | |
| 2 | ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង សំអាត | ប្រុស | អគ្គលេខាធិការ | អគ្គលេខាធិការដ្ឋាន គ ជ ប ជ | 097 726 9999 | |
| 3 | Mr. Arit Tatsaphan | M | Head of Human Trafficking Crime | Division 3 DSI | +66816562243 | [signature] |
| 4 | Miss Kannapat Kornhaew | F | Special case Inquiry Official | DSI | +66917904004 | [signature] |
| 5 | Mr Peeranus Pasatha | male | Special case officer | DSI | | [signature] |
| 6 | Ms. Kannika Suksomnil | F | Special case Inquiry Offial | DSI | +66958815050 | [signature] |
| 7 | Mr Yosson Ruangsunnyamsiri | M. | Special case officer | DSJ | +66874165195 | [signature] |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
អគ្គលេខាធិការដ្ឋាន

# បញ្ជីវត្តមាន

ថ្ងៃ ចន្ទ ០១ រោច ខែ ពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១

ត្រូវនឹងថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៨

ប្រជុំស្តីពី ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

| ល.រ | នាម គោត្តនាម/Name | ភេទ/Sex | តួនាទី/Position | អង្គភាព/Organization | លេខទូរស័ព្ទ/Phone | ហត្ថលេខា/Sign |
|---|---|---|---|---|---|---|
| 1 | លោកជំទាវ ជូ ប៊ុនអេង | ស្រី | អនុប្រធានអចិន្ត្រៃយ៍ | គណៈកម្មាធិការជាតិ គ ជ ប ជ | 012 872 639 | |
| 2 | ឯកឧត្តម នាយឧត្តមសេនីយ៍ ថោង សំអាត | ប្រុស | អគ្គលេខាធិការ | អគ្គលេខាធិការដ្ឋាន គ ជ ប ជ | 097 726 9999 | |
| 3 | Mr. Arit Tatsaphan | M | Head of Human Trafficking Crime | Division 3 DSI | +66816562247 | [signature] |
| 4 | Miss Kannapat Kornhaew | F | Special case Inquiry Official | DSI | +66917904004 | [signature] |
| 5 | Mr Peeranus Passatta | male | Special case officer | DSI | | [signature] |
| 6 | Ms. Kannika Suksomnil | F | Special case Inquiry Offial | DSI | +66958815050 | [signature] |
| 7 | Mr Yosson Ruangsunngamsiri | M. | Special case officer | DSI | +66874165195 | [signature] |